# មាតាបិតាក៏រាប់ផងដែរ

## ការជួយកូនរបស់លោកអ្នកនៅក្នុង –

## *លេខគណិត: លេខបូក លេខដក លេខគុណ និងលេខចែក*

តាមរយៈកិច្ចការប្រចាំថ្ងៃ និងសកម្មភាពលេងកុមារនឹងចេះប្រើលេខដោយខ្លួនឯងយ៉ាងងាយស្រួល។ កុមារតូចៗមានសមត្ថភាពណាស់ក្នុងការចែកចាយនូវរបស់ខ្លះៗ ដូចជាស្ករគ្រាប់ ដែលកុមារម្នាក់ៗមានចំណែកសមរម្យ ឬដាក់បញ្ចូលរបស់ដែលមិត្តភក្តិប្រមូលបាន ហើយគិតចំនួនសារុបដែលមាន។ យើងត្រូវជួយកុមារឲ្យចេះរុករកបានភ្លាមៗ និងវិធីងាយស្រួលនៃការប្រើលេខមួយចំនួន។



## តើកុមាររៀនចេះប្រើលេខដោយរបៀបណា?

នៅពេលរៀនប្រើលេខជាលើកដំបូង កុមារនឹងត្រូវការឲ្យមានរបស់ជាមួយខ្លួនដើម្បីបូក ដក គុណ ឬចែកចំនួនស្មើៗគ្នា(ចែក)។ គេនឹងឆ្លងកាត់ដំណើរនៃសេចក្ដីត្រូវការមើល និងរាប់ចំនួនរបស់នីមួយៗមួយម្ដងៗ។

យើងត្រូវការជួយកុមារឲ្យចេះរៀនចាប់ផ្ដើមរាប់ចំនួនធំៗ ហើយបូក ឬដកលេខទីពីរ។ យើងក៏ត្រូវជួយកុមាររៀបផ្គុំរូបភាពនៃ ក្រុម ឬចំនួនអ្វីមួយនៅក្នុងក្នុងគំនិតដើម្បីកុំឲ្យគេនៅតែពឹងផ្អែកទៅលើការមើលឃើញរបស់។ ការជួយកុមារឲ្យចេះប្រើគំនិតដើម្បី "ឃើញ" ចំនួនរបស់ច្រើន នឹងជួយឲ្យគេចេះយល់ទៅលើលេខគុណ និងលេខចែកផងដែរ មុននឹងគេរៀនចេះ "មេគុណ"។

# មាតាបិតាក៏រាប់ផងដែរ

## តើលោកអ្នកអាចធ្វើអ្វីបានខ្លះនៅផ្ទះ?

- លេងល្បែងពីលើក្តារបន្ទះដូចជា *Snakes and Ladders (ពស់ និងជណ្តើរ)* ដោយប្រើគ្រាប់ឡុកឡាក់ពីរ ហើយលើកទឹកចិត្តកូនរបស់លោកអ្នកឲ្យបូកលេខចំនួនពីរដែលបោះចំនោះចូលគ្នា។ បង្ហាញប្រាប់គេអំពីរបៀបរាប់ពីលេខធំទៅ។
- លេងល្បែងសន្លឹកបៀរដូចជា *21 or bust (២១ បើមិនដូច្នោះទេលេងចាញ់គេ)*។ នៅក្នុងល្បែងនេះ គេចែកបៀរពីរសន្លឹកទៅឲ្យអ្នកលេងម្នាក់ៗ ដែលត្រូវបូកលេខបញ្ចូលគ្នា។ អ្នកលេងម្នាក់ៗអាចស្នើសុំសន្លឹកបៀរបន្ថែមទៀតពី "ហិបវិភាគទាន" ដោយមានគោលបំណងកុំឲ្យជនដែលមានលេខច្រើនជាងគេ មានចំនួនលេខលើសពី២១។
- ចែកផ្លែឈើដូចជាផ្លែក្រូចទៅឲ្យកូនរបស់លោកអ្នក រួចហើយបូកចំនួនគ្រាប់ដែលលោកអ្នក និងកូនរបស់លោកអ្នកមាន។
- ប្រាប់ឲ្យកូនរបស់លោកអ្នកជួយគិតរកចំនួនរបស់ដែលត្រូវការ នៅពេលលោកអ្នកទៅផ្សារ។ *ខ្ញុំមានផ្លែប៉ោមចំនួន៦ តើខ្ញុំត្រូវការប៉ុន្មានទៀតដើម្បីឲ្យគ្រប់ចំនួន១០?*



- សម្លឹងមើលលេខផ្ទះនៅពេលដើរតាមផ្លូវថ្នល់។ សួរកូនរបស់ លោកអ្នកឲ្យប៉ាន់ស្មានលេខផ្ទះបន្ទាប់មួយទៀត។
- រៀបចំតុបាយសំរាប់មនុស្សម្នាក់ រួចប្រាប់ឲ្យកូនរបស់លោកអ្នករៀបចំចានឲ្យបានគ្រប់សំរាប់មនុស្សគ្រប់គ្នា។ សួរកូនរបស់លោកអ្នកថាតើត្រូវការចានប៉ុន្មានទៀត។
- រាប់ចំនួនស៊ុតដែលមាននៅក្នុងប្រអប់ បន្ទាប់ពីបានយកស៊ុតខ្លះចេញហើយសួរកូនរបស់លោកអ្នកថា *តើស៊ុតប៉ុន្មានត្រូវបានយកចេញ?*
- អានសៀវភៅមានទំព័រមាតិការឿងឲ្យកូនរបស់លោកអ្នកស្តាប់។ រកមើលសាច់រឿង ឬជំពូកនៅក្នុងទំព័រមួយ រួចគិតចំនួនទំព័រទៅទល់នឹងសាច់រឿងមួយទៀត។

# មាតាបិតាក៏រាប់ផងដែរ

- ប្រើស្តូលក្រដាសបង្គន់ ឬដបប្លាស្ទិកទទេ និងបាល់មួយដើម្បី លេងល្បែងលេងចោលកូនគោល។ លើកទឹកចិត្តឲ្យកូនរបស់លោកអ្នកប្រាប់លោកអ្នក ថាតើមានកូនគោលប៉ុន្មានត្រូវបានរំលំចុះ ហើយចំនួនប៉ុន្មានទៀតដែលមិនទាន់បានរំលំចុះ។ កត់ចុះចំនួនកូនគោលដែលត្រូវបានរំលំ ហើយចាំមើលថាតើនរណាជាអ្នកឈ្នះ។

- ច្រៀងចំរៀងដែលមានលេខ។ ប្រាប់ឲ្យកូនរបស់លោកអ្នកប្រាប់លោកអ្នកនូវលេខបន្ទាប់ទៀត ដែលមាននៅក្នុងចំរៀងនោះ មុននឹងច្រៀងឃ្លាបន្ទាប់ទៀត។

- បើកឡានដើរលេង រួចចង្អុលទៅសញ្ញាដែលបង្ហាញប្រាប់ចម្ងាយទៅនឹងតំបន់មួយទៀត។ នៅតាមជនបទ លេខបង្ហាញនៅតាមបង្គោលគីឡូម៉ែត្របន្ថយចុះម្តង៥គីឡូម៉ែត្រ។ ប្រាប់ឲ្យកូនរបស់លោកអ្នកគិតរកលេខនៅពីលើសញ្ញាបន្ទាប់ទៀត។

- ឲ្យកូនរបស់លោកអ្នកជួយចែកម្ហូបសំរាប់គ្រួសារ។ តើខ្ញុំត្រូវការនំភីស្សាចំនួនប៉ុន្មានដុំទៀតដើម្បីដើម្បីឲ្យម្នាក់ៗបានទទួលចំនួន២ដុំ។

- ប្រាប់ឲ្យកូនរបស់លោកអ្នកចែកចាយរបស់ឲ្យបានចំនួនស្មើគ្នា ជាមួយអ្នកឯទៀត។

- រាប់ចំនួនរបស់ដែលមាននៅក្នុងចំនួនរបស់ប្រមូលទុកមួយ ដូចជាសំបកលាសនៅក្នុងថង់ ឬឡេវអាវនៅក្នុងក្រឡធំមួយ។ សួរកូនរបស់លោកអ្នកថាតើមានវិធីងាយស្រួល ហើយរហ័សដើម្បីរាប់ចំនួនរបស់ទាំងនោះឬទេ ឧទាហរណ៍រាប់ម្តង៥។

- តុបតែងនំផែនដោយដាក់ផ្លែទំពាំងបាយជូរក្រៀម ឬគ្រាប់នំស្ពាតធី។ ដាក់ផ្លែទំពាំងបាយជូរក្រៀម និងគ្រាប់នំស្ពាតធីចំនួនដូចគ្នាពីលើនំនីមួយៗ ហើយសួរកូនរបស់លោកអ្នកឲ្យគិតរកចំនួនផ្លែទំពាំងបាយជូរក្រៀម និងគ្រាប់នំស្ពាតធីទាំងអស់ដែលលោកអ្នកនឹងត្រូវការ។

- រាប់ចំនួនដុំទឹកកកមាននៅក្នុងថាស។ ប្រសិនបើកូនរបស់លោកអ្នករាប់មួយម្តងៗ ប្រាប់ឲ្យគេរាប់ជាចំនួនជួរម្តងមាននៅក្នុងថាសនោះ។ (តាមធម្មតានេះនឹងត្រូវរាប់ម្តងពីរ)។

